រាជបណ្ឌិត្យសភាកម្ពុជា

# «ទិវានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១»

## ភាគទី៧ វគ្គទី៦


អត្ថបទចងក្រងដោយ៖ លោកស្រី **ស៊ិន ច័ន្ទអមរា**

មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាបណ្ឌិត្យសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា




ប្រភពរូបភាព : http://km.rfi.fr/cambodia/2018.11.11

នៅក្នុងភាគទី៧ វគ្គទី៦នេះ យើងសូមលើកយកនូវសុន្ទរកថារបស់លោកដុកទ័រវ៉ាលឡេត់ (Docteur Vallet) ជាចាងហ្វាងក្រុមសមាគមពួកពិជ័យសង្គ្រាមចាស់[1] ដែលត្រូវថ្លែងបន្ទាប់ពីសង្កថារបស់ព្រះបាទសម្ដេចស៊ីសុវត្ថិ។ ពាក្យដែលលោកបានយកមកនិយាយនៅក្នុងសុន្ទរកថានោះ លោកវ៉ាលឡេត់បានរំឭកអំពីទុក្ខវេទនានៅក្នុងសង្គ្រាមលោកលើកទី១ រយៈពេល៥០ខែ កាលដែលបានទៅច្បាំង តទល់នឹងប្រទេសអាល្លឺម៉ង់។ រួមជាមួយសហការីរបស់លោក ដែលមានសំណាងបាននៅរស់នោះ លោកបានថ្លែងដោយខ្សឹកខ្សួលទៅកាន់អ្នកដែលអនិច្ចកម្មដោយចិត្តក្លាហាន នៅក្នុងសង្គ្រាមនោះ។

## ៧-៤-សុន្ទរកថារបស់លោកចាងហ្វាងក្រុមសមាគមពួកពិជ័យសង្គ្រាមចាស់[2]

សូមទ្រង់ព្រះករុណា។
សូមលោកឡឺរេស៊ីដង់ សុប៉េរីយ៉ើរ។
សូមអស់លោក អស់អ្នក អស់មិត្តភក្តិ សូមទ្រង់ជ្រាប សូមបានជ្រាប។

ដោយខ្ញុំមានសេចក្ដីគាប់ចិត្តជាផ្លូវកតញ្ញូ ព្រមទាំងសេចក្ដីរំជួលចិត្តជាខ្លាំង បានជាខ្ញុំអធិប្បាយនៅចំពោះព្រះភក្ត្រព្រះករុណា ចំពោះមុខអស់លោក អស់អ្នកទាំងអស់ ក្នុងថ្ងៃនេះ ដើម្បីធ្វើឱ្យរុងរឿងដល់អ្នកមានថ្វីដៃ ដែលយើងត្រូវនឹកគុណពុំភ្លេចនេះ។

ប៉ុន្តែដោយខ្ញុំចង់ឱ្យអ្នកទាំងអស់គ្នា មានសេចក្ដីរំជួលចិត្តនឹងឫសម្ដីឈឺឆ្អាលជាមាំរបស់ខ្ញុំផងនោះ ខ្ញុំមានចិត្តសង្ឃឹមជាប្រាកដថា អ្នកទាំងអស់គង់មានសេចក្ដីដឹងគុណ និងអាសូរមេត្តាករុណាដល់អ្នកដែលប្រថុយជីវិតស្លាប់នឹងព្រះមហានគរ (ប្រទេសបារាំង) ដើម្បីនឹងការពារព្រះមហានគរ ឱ្យជៀសសេចក្ដីសង្កត់សង្កិន និងអាប់ឱន ពីដៃអ្នកប្រទេសក្រៅ។

វិមាននេះបានកសាងជូនចំពោះអ្នកប្រថុយជីវិតដែលមានថ្វីដៃដ៏ប្រសើរ ហើយដែលលោក ឌុយក្វាំង (Ducoing) បានយកចិត្តទុកដាក់ជាទីបំផុត ខំធ្វើឱ្យអស់ពីចិត្តឱ្យបានកើតឡើងដូច្នេះ។ យើងតោងនឹកមូលគ្នាគោរពប្រណិប័តន៍ ដល់អ្នកដែលមានថ្វីដៃក្នុងសង្គ្រាមធំនេះ។ ខ្ញុំមានចិត្តបំណងចង់ធ្វើឱ្យបាន

---

[1] គឺប្រធានសមាគមពួកពិជ័យសង្គ្រាមចាស់ (Président de l’Association des Anciens Tirailleurs)។

[2] បុន្យឆ្លងវិមានដែរសាងក្នុងក្រុងក័ម្ពុជាធិប្ដី, ជាទីរំឭកដល់អស់អ្នក ដែលទទួលអនិច្ចកម្ម ក្នុងចំបាំងធំ(ពីឆ្នាំ១៩១៤ដល់ឆ្នាំ១៩១៨), នៅក្នុងរាជកិច្ចរាជការ ឆ្នាំ១៩២៥ ទំព័រ៩៧-១០១។

ថ្កុំថ្កើងរុងរឿង តាមបំណាច់[3]ដល់មិត្រភក្តិយើងទាំងនេះ ដែលយើងគង់តែនឹងចាំឈ្មោះពុំភ្លេចក្នុងចិត្តយើងបានយូរអង្វែង ដូចមានឈ្មោះឆ្លាក់នៅលើថ្មកែវនេះស្មើគ្នា ដោយមិត្តភក្តិយើងបានដល់នូវ សេចក្តីមរណកាលក្នុងពិជ័យសង្គ្រាម ដែលតយុទ្ធនៅស្រុកបារាំងសែស និងស្រុកទិសបូព៌(អូរីអង្គ)[4] ព្រោះបានការពារក្នុងអាណាប្រជាជនក្នុងជម្ពូទ្វីប។ ឯភាសាមនុស្សយើងនោះ គ្មានភាសាណាដែលយកមកនិយាយប្រដូចនឹងថ្វីដៃដ៏ប្រសើរនេះបាន

ឡើយ។ ដោយខ្ញុំមានចិត្តកើតទុក្ខជាខ្លាំងនោះ បានជាខ្ញុំមានសេចក្តីដឹងគុណ និងមេត្តាករុណាចំពោះអ្នកស្លាប់ទាំងនេះ។ បានជាខ្ញុំនឹកឃើញពាក្យទាំង២ម៉ាត់នេះឡើងវិញ ហើយបានជាអធិប្បាយដោយគោរពដោយស្មោះយ៉ាងនេះ ព្រោះខ្ញុំមានសេចក្តីរំជួលចិត្តជាងអ្នកផងទាំងអស់ ដោយសារមានភាពស្និទ្ធស្នាលជាមួយអ្នកទាំងនេះ កាលដែលខ្ញុំបានទៅច្បាំងដែរ។

អ្នកដែលមានអាយុពុំត្រូវការ[5] ឬអ្នកដែលមានអាការរោគក្នុងខ្លួន ឬអ្នកដែលជាប់ធ្វើការមុខក្រសួងនានាពុំបានទៅចូលច្បាំងក្នុងរវាង៤ឆ្នាំនោះ ក៏គង់តែឈ្វេងយល់ឃើញនូវសេចក្តីស្លាប់ដែលមកបៀតបៀនក្នុងខណៈនោះជានិច្ច។ ក្នុងថ្ងៃនេះគួរយើងទាំងអស់គ្នាគិតនឹកដឹងគុណ និងមេត្រីដ៏ប្រសើរដល់អ្នកដែលស៊ូប្តូរជីវិត ប្តូរទ្រព្យសម្បត្តិជួសយើង ហើយយើងត្រូវបែរមុខទៅកាន់អ្នកដែលបាត់បង់ជីវិតទាំងនេះដោយតាំងចិត្តឱ្យស្មោះសរ ដោយសេចក្តីកតញ្ញូ និងសេចក្តីនឹករលឹកដោយគោរព ទៅដល់អ្នកទាំងនេះ ពីព្រោះគេ៖ បានការពារយើង, បានធ្វើឱ្យវិនាសចំពោះការគ្រប់គ្រងទាំងរំលោភបំពានរបស់សត្រូវ, បានយកគំនរខ្មោចដែលស្លាប់ទាំងនោះទៅទប់ទល់ធ្វើឱ្យឈ្នះសត្រូវបាន។ ទោះព្រលឹមព្រាងៗក្តី ទោះយប់ងងឹតក្តី ក៏បុគ្គលទាំងនេះស៊ូតែរត់ពីក្នុងដី ជាប់ផុកជាប់ឈាមទៅរកសេចក្តីស្លាប់ ពុំមានញញើតដល់តិចឡើយ។ ទោះច្បាំងនៅស្រុក«ឡាម៉ានន៍»(La Marne)ក្តី ទៅស្រុក«វែរដេង»(Verdun)ក្តី ក៏ចេះតែខំស្រែកគំរាម ឱ្យពួកសត្រូវដូច្នេះថា«ចូលពុំបានទេ»។

ឱអ្នកអនិច្ចកម្មក្នុងចម្បាំងធំអើយ! ដែលស្លាប់ជាច្រើននៅនាទីចម្បាំង នៅវេលាស្រុកកើតវិបរិត[6]

---

[3] បំណាច់គឺ ថ្វីដៃ ឬស្នាដៃ វចនានុក្រមខ្មែរ ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧ ទំព័រ៥៩៣។

[4] ស្រុកទិសបូព៌ (អូរីអង្គ) គឺនៅបូព៌ាប្រទេស (Les pays de l’Orient)។

[5] អ្នកដែលមានអាយុលើសពីតម្រូវការឱ្យធ្វើទាហាន។

[6]វិបរិត គឺដែលប្រែប្រួល វចនានុក្រមខ្មែរ ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧ ទំព័រ ១១៩០។

ហើយស្លាប់ដោយមានចិត្តសង្ឃឹមជាប្រាកដថានឹងមានជ័យជម្នះ ក៏ខំស៊ូប្តូរជីវិតរបស់អ្នកឱ្យខាងតែបាន រួចពីខ្ញុំកញ្ជះគេ និងរួចពីកណ្តាប់ដៃមនុស្សជាសត្រូវគ្មានមេត្តាករុណា។ យើងក៏សូមសម្តែងនូវសេចក្តីកតញ្ញូដឹងគុណ និងសេចក្តីមេត្រីរបស់យើង ចំពោះអ្នកនៅរស់រានមានជីវិតទាំងបារាំងទាំងខ្មែរ ដែលមានចិត្តក្លាហានដូចគ្នា។ ថ្វីដៃដែលអ្នកបានធ្វើទាំងប៉ុន្មាននេះ មានជ័យជម្នះលើសាសន៍មោហោដែលមកសង្កត់សង្កិនអាណាប្រជានុរាស្ត្រយើង។

ឯសេចក្តីអធិប្បាយសរសើរទាំងនេះ ក៏គង់តែនឹងភ្លេចពុំខាន។ មានតែវិមានសំរឹទ្ធិ៍នេះឯងហើយដែលធ្វើឱ្យបានគង់កេរតទៅ ព្រោះវិមាននេះអាចនឹងរំឭកអ្នកណាដែលភ្លេចឱ្យចាំឈ្មោះអ្នកដែលស្លាប់នោះឡើងវិញ។ វិមាននេះក៏អាចធ្វើឱ្យអ្នកឯទៀតចាំសេចក្តីមេត្តាករុណាឱ្យបានយូរអង្វែង ដែលជាកិច្ចរបស់អ្នកទាំងអស់។

ម៉្យាងទៀត វិមាននេះធ្វើឱ្យអ្នកនៅក្រោយៗ ដឹងកិច្ចការដែលបានជួយធុរៈគ្នាទៅវិញទៅមកទាំងបារាំងទាំងខ្មែរ ដែលបានស៊ូប្តូរជីវិតដើម្បីឱ្យបានសេចក្តីយុត្តិធម៌ និងសេចក្តីរួចខ្លួនធ្វើអ្វីៗបានតាមចិត្ត។

ខ្ញុំមានចិត្តចង់ស្លេះ[7]សេចក្តីអធិប្បាយនេះត្រឹមនេះ។

(សូមរង់ចាំអានភាគបន្ត…)

[7]ស្លេះ គឺឈប់បង្អង់ទុកដោយឡែកឬដោយអន្លើសិន វចនានុក្រមខ្មែរ ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧ ទំព័រ ១៥៩៥។